# *ការយល់ដឹងអំពីសិទ្ធិរបស់ខ្លួនចំពោះការពិនិត្យប្រវត្តិរបស់កម្មករកំពង់ផែ និងអ្នកបើកបររថយន្តដឹកទំនិញ នៃនាយកដ្ឋានសុវត្ថិភាពលើការដឹកជញ្ជូន ដើម្បីទទួលបាននូវ TWIC ជាថ្មីឡើងវិញ*

▶ **តើទោសឧក្រិដ្ឋមួយណាដែលនាំឱ្យកម្មករបាត់បង់លក្ខណៈសម្បត្តិទទួលបាននូវលិខិតសំគាល់ប្រចាំខ្លួនជាថ្មីថាជាកម្មករដឹកជញ្ជូន (TWIC)?** បើអ្នកធ្លាប់បានប្រព្រឹត្ត ទោស ឧក្រិដ្ឋក្នុងរយៈពេល7ឆ្នាំចុងក្រោយ (ឬបានត្រូវអាជ្ញាធរដោះលែងពីពន្ធនាគារក្នុងកំឡុងពេល 5ឆ្នាំចុងក្រោយ) ដែលពាក់ព័ន្ធទៅនឹង បទឧក្រិដ្ឋណាមួយលើ “ការគំរាមកំហែងសន្តិសុខសង្គម” អ្នកអាចបាត់បង់សិទ្ធិពីការទទួលបាននូវ TWIC ។ បទឧក្រិដ្ឋមួយចំនួនធំដែលនាំឱ្យអ្នកបាត់បង់សិទ្ធិ មានដូចជាការលក់ថ្នាំញៀន ការកាន់កាប់អាវុធខុសច្បាប់ ការគៃបន្លំ (មិនរួមបញ្ចូលនូវការគៃបន្លំផ្នែកជំនួយសុខមាលភាព ឬសរសេរសែកបើកលុយបន្លំ) និងបទឧក្រិដ្ឋផ្សេងទៀត ចំពោះទោសកម្មលើ “ភាពមិនស្មោះត្រង់” ។

▶ **តើស្ថានភាពអន្តោប្រវេសន៍បែបណាទើបមានលក្ខណៈសម្បត្តិអាចទទួលបាននូវ TWIC ឡើងវិញ?** ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបាននូវ TWIC អ្នកត្រូវ តែជាពលរដ្ឋអាមេរិក ជាអ្នកតាំងទីលំនៅជាអចិន្ត្រៃយ៍ស្របច្បាប់លើទឹកដីអាមេរិក ជាជនភៀសខ្លួន ជាអ្នកស្វែងរកសិទ្ធិជ្រកកោន ជាអន្តោប្រវេសន៍ដែលបាន ទទួលការអនុញ្ញាតិឱ្យធ្វើការនៅលើទឹកដីអាមេរិកបានដោយគ្មានល័ក្ខណ្ឌ (លើកលែងតែ S-5, S-6, K-1, K-2) ឬជាជនអន្តោប្រវេសន៍ដែល បានទទួលការអនុញ្ញាតិ ឱ្យធ្វើការបាន តែមានល័ក្ខណ្ឌជាក់លាក់ណាមួយ (រួមទាំង H-1B, H-1B1, E-1, L-1, O-1 និងអ្នកដែលកាន់ទិដ្ឋាកាជាក់លាក់ផ្សេងទៀត) ។ ក្នុងករណីខ្លះ កម្មករដែលបានទទួលឋានៈការការពារបណ្តោះអាសន្ន (TPS) ក៏អាចមាន លក្ខណៈសម្បត្តិទទួលបាននូវ (TWIC) នេះដែរ ។

▶ **ប្រសិនបើអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយសារតែអ្នកមានប្រវត្តិប្រព្រឹត្តិបទឧក្រិដ្ឋ អ្នកមានសិទ្ធិដាក់ពាក្យសុំក្នុងឋានៈជាអ្នកបដិសេធលើបទឧក្រិដ្ឋដែលបានប្រព្រឹត្តិ ។** មានដំណើរការពិសេសរបស់ “អ្នកបដិសេធ” ដែលអ្នកអាចយកមកប្រើដើម្បីបង្ហាញថា អ្នកគួរតែបានទទួលនូវ TWIC ពីព្រោះអ្នកមិនមែនជាភេរវិករដែលគំរាមកំហែងដល់សន្តិសុខសង្គមឡើយ ។ កម្មករដែលមានប្រវត្តិប្រព្រឹត្តិបទឧក្រិដ្ឋ តែគ្មានពាក់ព័ន្ធលើបញ្ហាផ្សេងទៀត ហើយមានប្រវត្តិការងារល្អ នឹងមានឱកាសច្រើនក្នុងការបានទទួលនូវសិទ្ធិជាអ្នកបដិសេធ ពីនាយកដ្ឋានសុវត្ថិភាពលើការដឹកជញ្ជូន (TSA) ។ បើអ្នកជា កម្មករអន្តោប្រវេសន៍ ហើយត្រូវនាយកដ្ឋានបដិសេធចោល ដោយសារតែអ្នកបានទទួលឋានៈការការពារបណ្តោះអាសន្ន (TPS) អ្នកត្រូវតែដាក់ពាក្យសុំជាអ្នកបដិសេធ ដើម្បីឱ្យខ្លួនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបាននូវ TWIC ដូចកម្មករដទៃ។

▶ **ប្រសិនបើ TSA សរសេរខុសអំពីប្រវត្តិការប្រព្រឹត្តិបទឧក្រិដ្ឋ ឬស្ថានភាពអន្តោប្រវេសន៍របស់អ្នក អ្នកមានសិទ្ធិប្តឹង ឧទ្ធរណ៍ បាន។** នៅ TSA គេមានដំណើរការប្តឹង “ឧទរណ៍” ដែលអាចជួយដល់កម្មករជាច្រើនដែលបានទទួលការបដិសេធខុសចំពោះសិទ្ធិទទួលបាននូវ TWIC ដោយសារតែការកត់ត្រាលើការប្រព្រឹត្តិបទឧក្រិដ្ឋរបស់អ្នកនោះ ធ្វើឡើងដោយមិនគ្រប់គ្រាន់ ឬមិនត្រឹមត្រូវ ដែល FBI ជាអ្នកប្រគល់ឱ្យ ការយកពតិមានដែលមិនត្រឹមត្រូវពីក្នុងទិន្នន័យអន្តោប្រវេសន៍ ឬកំហុសសាម័ញ្ញផ្សេងទៀត ។ លទ្ធផលនៃការប្តឹងឧទរណ៍ភាគច្រើន TSA កែតម្រូវឡើងវិញនូវរាល់កំហុសទាំងនោះ ហើយផ្តល់ TWIC ជូនដល់កម្មករដែលរងគ្រោះទាំងអស់ឡើងវិញ ។

▶ **ប្រសិនបើ TSA បដិសេធមិនផ្តល់ឱ្យអ្នកនូវ TWIC ទេ សូមកុំភ្លេច ដាក់ពាក្យប្តឹងឧទ្ធរណ៍ ឬដាក់ពាក្យជាអ្នកបដិសេធ!** ចំពោះពិតមានបន្ថែម សូមទំនាក់ទំនង [សរសេរអាស័យដ្ឋានទំនាក់ទំនងប្រចាំមូលដ្ឋាននៅទីនេះ] ។